# ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ៊ា

**ការិយាល័យផ្នែក កម្មវិធីសិក្សា និងការវាយតម្លៃ**

440 North Broad Street, Suite 251
Philadelphia, PA 19130

Donna Runner
នាយិការង ស្តីទី

ទូរស័ព្ទ៖ ២១៥-៤០០-៤២១០
ទូរសារ៖ ២១៥-៤០០-៤២១២


ជូនចំពោះ មាតាបិតា/អាណាព្យាបាល របស់សិស្សានុសិស្សថ្នាក់ទី៩ បច្ចុប្បន្ន៖

ក្រសួងអប់រំនៃរដ្ឋផិនស៊ីលវេញ៉ា បានអនុវត្តការប្រឡង ឃីស្តូន (Keystone) ថ្មី ជំនួសប្រព័ន្ធនៃការវាយតម្លៃសាលារបស់រដ្ឋផិនស៊ីលវេញ៉ា (PSSA) សម្រាប់សិស្សថ្នាក់ទី១១។ ការប្រឡង ឃីស្តូន គឺជាការវាយតម្លៃនៅពេលរៀនចប់មុខវិជ្ជា រៀបចំឡើងដើម្បីវាយតម្លៃការស្ទាត់ជំនាញក្នុងការសិក្សាមុខវិទ្យាសំខាន់ៗ។ ចាប់ផ្តើមជាមួយសិស្សានុសិស្សដែលនឹងបញ្ចប់ការសិក្សានៅឆ្នាំ២០១៧ (សិស្សានុសិស្សថ្នាក់ទី៩ បច្ចុប្បន្ន) សិស្សានុសិស្សត្រូវបង្ហាញឲ្យឃើញនូវភាពស្ទាត់ជំនាញចំពោះមុខវិទ្យា ពិជគណិត១ អក្សរសាស្ត្រ និងជីវវិទ្យា (Algebra I, Literature, Biology) នៃការប្រឡង ឃីស្តូន ទើបអាចបញ្ចប់ការសិក្សាបាន។ ដោយមូលហេតុនេះហើយ តម្រូវការថ្មីនេះនឹងពាក់ព័ន្ធដល់ការបញ្ចប់ការសិក្សារបស់កូនលោកអ្នកពីវិទ្យាល័យ។

សិស្សានុសិស្សដែលបានចុះឈ្មោះរៀនមុខវិទ្យាដែលទាក់ទងនឹង ឃីស្តូន (ពិជគណិត១/Algebra I អង់គ្លេស២/English 2 ជីវវិទ្យា/Biology) ត្រូវគេតម្រូវឲ្យប្រឡង (ពិជគណិត១ អក្សរសាស្ត្រ និងជីវវិទ្យា) របស់ ឃីស្តូន នៅពេលរៀនចប់មុខវិជ្ជា។ ដោយសារសិស្សានុសិស្សថ្នាក់ទី៩ បច្ចុប្បន្នភាគច្រើនបានចុះឈ្មោះរៀនពិជគណិត១ ពួកគេនឹងប្រឡង ឃីស្តូន សម្រាប់ ពិជគណិត១ នៅឆ្នាំនេះ។ នៅឆ្នាំបន្តបន្ទាប់ទៀត នៅពេលដែលពួកគេរៀនចប់មុខវិជ្ជា ជីវវិទ្យា និងអង់គ្លេស២ ពួកគេនឹងប្រឡង ឃីស្តូន សម្រាប់ ជីវវិទ្យា និងអក្សរសាស្ត្រ។

បើសិនជាសិស្សានុសិស្សប្រឡង ឃីស្តូន ធ្លាក់ លើកទីមួយ ពួកគេអាចមានឱកាសប្រឡងជាច្រើនដងទៀត មុនពេលពួកគេបញ្ចប់ការសិក្សា។ ទោះជាដូច្នេះក៏ដោយ នៅខែមិថុនានៃឆ្នាំបញ្ចប់ការសិក្សារបស់ពួកគេពីវិទ្យាល័យ ពួកគេ**ត្រូវ**ប្រឡងឲ្យជាប់ មុខវិទ្យាទាំងបី របស់ ឃីស្តូន។

បើសិនជាលោកអ្នកមានសំណួរអ្វីអំពីការប្រឡង ឃីស្តូន សូមទាក់ទង assessment@philasd.org។